អង្គការអភិវឌ្ឍន៍សំលេងសហគមន៍

**គម្រោង៖** បង្កើនជីវភាពរស់នៅរបស់សហគមន៍ តាមរយៈអេកូទេសចរណ៍ និងការអភិរក្សធនធានធម្មជាតិ

## របាយការណ៍ករណីសិក្សា

## សហគមន៍អេកូទេសចរណ៍ និងការអភិរក្សធនធានធម្មជាតិ – ស្រ្តីក្នុងសហគមន៍ព្រៃធំអន្លង់ថ្ម

## ១. សេចក្តីផ្តើម

សហគមន៍តំបន់ការពារធម្មជាតិព្រៃធំអន្លង់ថ្ម ត្រូវបានបង្កើតឡើងនៅឆ្នាំ ២០០៦ ដោយមានការគាំទ្រ និងសម្របសម្រួលពីមន្ទីរបរិស្ថាន និងការគាំទ្របច្ចេកទេសពីក្រសួងបរិស្ថាន។ រហូតមកដល់បច្ចុប្បន្ន គណៈកម្មការសហគមន៍ត្រូវបានជ្រើសតាំងចំនួន ៤ អាណត្តិ ហើយមានសមាសភាពសរុប ០៩ រូប ក្នុងនោះស្រី ០៣ រូប។

សហគមន៍មានផ្ទៃដីសរុប ៥០៦ ហិកតា និងទទួលបានប្រកាសទទួលស្គាល់ពីក្រសួងបរិស្ថាន។ អ្នកទទួលផលសរុបមានចំនួន ៦២៥នាក់។ សមាជិកសហគមន៍ភាគច្រើនមានមុខរបរធ្វើស្រែចម្ការ ចិញ្ចឹមសត្វ ប្រមូលអនុផលព្រៃឈើ កម្មកររោងចក្រ កម្មករលក់កម្លាំងពលកម្ម និងចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេស។ សហគមន៍កំពុងប្រឈមមុខនឹងបញ្ហាជាច្រើន រួមមាន៖ ខ្វះដៃគូអភិវឌ្ឍន៍ ខ្វះធនធានថវិកា និងធនធានមនុស្ស និងជាពិសេសខ្វះសមត្ថភាពបច្ចេកទេសក្នុងការគ្រប់គ្រង និងដឹកនាំ។

ក្នុងចំណោមគ្រួសារសមាជិក មានគ្រួសារក្រីក្រ (ក្រ១) ចំនួន ១៣ គ្រួសារ និង (ក្រ២) ចំនួន ១៥ គ្រួសារ។ ប្រជាជនចំណាកស្រុកក្នុងឃុំមានសរុប ៣០៣ នាក់ ក្នុងនោះស្រី ១៨១ នាក់។ ដោយឡែក ភូមិជីពូក និងភូមិងយ មានប្រជាជនចំណាកស្រុកសរុប ២៨ នាក់ ស្រី ១២ នាក់។ ភូមិទាំងពីរនេះជួបប្រទះបញ្ហារាំងស្ងួត គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ ដែលបណ្តាលឱ្យទិន្នផលកសិកម្មធ្លាក់ចុះជាបន្តបន្ទាប់ និងខ្វះទឹកស្រោចស្រពក្នុងរដូវប្រាំង។ បញ្ហាទាំងនេះបានជះឥទ្ធិពលដល់ជីវភាពរស់នៅ និងបណ្តាលឱ្យសមាជិកមួយចំនួនងាកទៅរកសកម្មភាពខុសច្បាប់ ដូចជា កាប់ឈើ បរបាញ់សត្វព្រៃ និងរុករានដីសហគមន៍។

## ២. ព័ត៌មានទូទៅអំពីអ្នកស្រី អ៊ុជ កុសល់ មុនចូលរួមជាមួយគម្រោង GEF

អ្នកស្រី អ៊ុជ កុសល់ អាយុ ៣២ឆ្នាំ រស់នៅនិងភូមិងយ ឃុំក្បាលទឹក ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ជាសមាជិកគណៈកម្មការសហគមន៍ព្រៃធំអន្លុងថ្ម ។ លោកស្រី អ៊ុជ កុសល់ មានមុខរបរជាកសិករ បានចូលរួមជាមួយគម្រោង GEF ចាប់តាំងពីឆ្នាំ ២០២៤ មកដល់បច្ចុប្បន្នដែលមានរយៈពេលជាងមួយឆ្នាំ ក្នុងតួនាទីជាសមាជិកគណៈកម្មការសហគមន៍ព្រៃធំអន្លុងថ្ម។ មូលហេតុដែលលោកស្រីចូលរួមជាមួយសហគមន៍ព្រៃធំអន្លុងថ្មគឺដោយសារមានបំណងចង់ឱ្យសហគមន៍មានការរីកចម្រើន ចង់ចូលរួមការពារព្រៃឈើឱ្យបានគង់វង្ស ចង់ទទួលបានចំណេះដឹង និងបទពិសោធន៍អំពីសារៈប្រយោជន៍ធនធានធម្មជាតិ និងបង្កើនប្រាក់ចំណូលគ្រួសារតាមរយៈអេកូទេសចរណ៍ ដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅរបស់គ្រួសារ។

មុនចូលរួមសហគមន៍ព្រៃធំអន្លង់ថ្ម លោកស្រីមិនទាន់មានការយល់ដឹងគ្រប់គ្រាន់អំពីសារៈសំខាន់នៃការអភិរក្សព្រៃឈើ និងបរិស្ថាន។ ទោះបីធ្លាប់ឃើញបទល្មើសព្រៃឈើកើតមាន ក៏មិនបានចូលរួមទប់ស្កាត់ ឬរាយការណ៍ទៅអាជ្ញាធរពាក់ព័ន្ធ ដោយគិតថាមិនមែនជាតួនាទីរបស់ខ្លួន។ អ្នកស្រីមិនមានបច្ចេកទេសដាំដំណាំ ការដាំដំណាំរបស់អ្នកស្រីធ្វើតាមទម្លាប់ពីបទពិសោធន៍កន្លងមក។ អ្នកស្រីក៏មិនចេះពីរៀបនៃការសន្សំប្រាក់ផងដែរ។



## ៣. ក្នុងអំឡុងពេលចូលរួមសកម្មភាពជាមួយគម្រោង

ចាប់ពីឆ្នាំ ២០២៤ បន្ទាប់ពីសហគមន៍ព្រៃធំអន្លង់ថ្ម ទទួលបានគម្រោងកម្មវិធី GEF អ្នកស្រីបានចូលរួមយ៉ាងសកម្មក្នុងសកម្មភាពនានា និងទទួលបានការបណ្តុះបណ្តាលពង្រឹងសមត្ថភាព និងជំនាញជាច្រើន។ ការបណ្តុះបណ្តាលរួមមាន ការយល់ដឹងអំពីការបម្រែបម្រួលអាកាសធាតុ និងការអភិវឌ្ឍអេកូទេសចរណ៍ បច្ចេកទេសដាំដំណាំ និងរបៀធ្វើជីធម្មជាតិ (ជីកំប៉ុស្ត) ជាមួយនឹងការទទួលបានធ្នើសម្រាប់ដាំដំណាំ។ ក្រៅពីទទួលបានការបណ្តុះបណ្តាល អ្នកស្រីក៏បានចូលរួមអនុវត្តសកម្មភាពជាច្រើនជាមួយនឹងសហគមន៍ព្រៃធំអន្លុងថ្ម ដូចជា ការដើរល្បាតព្រៃដើម្បីទប់ស្កាត់បទល្មើសព្រៃឈើដែលអាចកើតមានឡើង ការចូលរួមដាំកូនឈើ ការចូលរួមការពារ និងថែរក្សាព្រៃឈើសហគមន៍ ការកាប់ឆ្ការព្រៃតូចៗ និងបង្កើតផ្លូវការពារភ្លើងឆេះព្រៃ ជាពិសេសបានចូលរួមធ្វើការផ្សព្វផ្សាយអំពីការប្រែប្រួលអាកាសធាតុ និងសារៈសំខាន់នៃថែរក្សាព្រៃឈើ។ មិនត្រឹមតែចូលរួមក្នុងសកម្មភាពទាំងនោះទេ អ្នកស្រីក៏បានចូលរួមក្នុងក្រុមសន្សំប្រាក់សហគមន៍ផងដែរ។





### ៤. ការប្រែប្រួល បន្ទាប់ពីអ្នកស្រី អ៊ុជ កុសល់ បានចូលរួមជាមួយគម្រោង GEF

ដោយសារតែលោកស្រីទើបតែចូលរួមជាមួយសហគមន៍ព្រៃធំអន្លង់ថ្ម ក្នុងអំឡុងពេលដែលសហគមន៍ទទួលបានគម្រោង GEF អ្នកស្រី អ៊ុជ កុសល់ ការផ្លាស់ប្តូរអ្នកស្រីមិនទាន់បានច្រើនទេ។ អ្វីដែលអ្នកស្រីមានការផ្លាស់ប្តូនោះមានដូជា ជីវភាពគ្រួសារមានភាពល្អប្រសើជាមុនតាមរយៈការដាំបន្លែដែលរួមចំណែកកាត់បន្ថយចំណាយទៅការលើទិញបន្លែនៅទីផ្សារដែលជាបន្លែគ្មានសុវត្ថិភាព។ អ្នកស្រីមានការកើនឡើងនូវទំនុកចិត្ត និងក្លាហានក្នុងការចូលរួមសម្រេចចិត្តជាមួយសហគមន៍ព្រៃធំអន្លង់ថ្មច្រើនជាងមុន ព្រមទាំងធ្វើអោយអ្នកស្រីកាន់តែស្រឡាញ់ខ្លាំងឡើងអំពីការចូលរួមជាមួយសហគមន៍ និងការការពារធនធានធម្មជាតិ។ លើសពីនេះទៅទៀតអ្នកស្រីចេះចាប់ផ្តើមសន្សំប្រាក់ និងអាចគ្រប់គ្រងហិរញ្ញវត្ថុគ្រួសារបានល្អប្រសើផងដែរ។

**សម្រង់សម្តីលោកស្រីអ៊ុជ កុសល់:**

"ការចូលរួមក្នុងគម្រោងនេះបានធ្វើឱ្យខ្ញុំមានទំនុកចិត្តលើខ្លួនឯង កាន់តែស្រឡាញ់ព្រៃឈើ និងអាចជួយបង្កើនចំណូលគ្រួសារបាន។ ខ្ញុំសង្ឃឹមថាស្ត្រីផ្សេងៗទៀតនឹងចូលរួមដើម្បីអភិវឌ្ឍសហគមន៍យើងឱ្យកាន់តែប្រសើរ។"

### ៥. សំណូមពរ និងអនុសាសន៍របស់អ្នកស្រី អ៊ុជ កុសល់

គម្រោង GEF បានចូលរួមយ៉ាងសំខាន់ក្នុងការលើកកម្ពស់ជីវភាពសហគមន៍ និងពង្រឹងសមត្ថភាពស្ត្រី។ ដោយសារការទទួលបានគាំទ្រពីគម្រោង GEF ទើតែបានជាងមួយឆ្នាំ ដំណើការនៃការអនុវត្តរបស់ គណៈកម្មការមិនទាន់មានភាពរលូន ជាពិសេសសមត្ថភាពរបស់សមាជិកគណៈកម្មការសហគមន៍ព្រៃធំ អន្លុងថ្មនៅមានកំរិត លោកស្រីសំណូមពរដល់គម្រង GEF គាំទ្របន្តលើបច្ចេកទេសនៃការគ្រប់គ្រងនិងដឹកនាំរបស់សមាជិកគណៈកម្មការសហគមន៍ព្រៃធំអន្លង់ថ្ម និងធនធានហិរញ្ញវត្ថុ ដើម្បីជានានិរន្តរភាពរយៈពេលវែងដែលអាចធ្វើអោយសហគមន៍ដំណើការដោយខ្លួនឯងបានបន្ទាប់ពីគម្រោងបញ្ចប់ការគាំទ្រ។

**រៀបចំដោយ៖ លោកស្រី ជួប ចន្ទី** ក្រុមអ្នកវាយតម្លៃឯករាជ្យ ART